# តារាងស្តីពីព័ត៌មានរបស់គម្រោង

លេខPIP : 692

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

## ផ្នែក ក

*(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)*

១. ឈ្មោះគម្រោង : អភិវឌ្ឍន៍គោលនយោបាយពាណិជ្ជកម្មដែលមានលក្ខណៈបត់បែន ដើម្បីជំរុញការធ្វើពិពិធកម្មសេដ្ឋកិច្ច និងពាណិជ្ជកម្មឱ្យបានទូលំទូលាយ

២. កាលបរិច្ឆេទគម្រោង

| | |
|---|---|
| កាលបរិច្ឆេទចាប់ផ្តើមគម្រោង | 03/01/25 |
| កាលបរិច្ឆេទបញ្ចប់គម្រោង | 01/01/27 |
| ៣. ចំណាយគម្រោងសរុប | $693,000 |
| ៤. ស្ថាប័នទទួលខុសត្រូវ | ក្រសួងពាណិជ្ជកម្ម |
| RESPONSIBLE UNIT | Department of Trade Policy |
| អង្គភាពទទួលខុសត្រូវ | នាយកដ្ឋានគោលនយោបាយពាណិជ្ជកម្ម |
| ៥. ស្ថានភាពគម្រោង | គម្រោងសម្រាប់អនុវត្តផ.យ.អ.ជ. |

ព័ត៌មានលម្អិតអំពីគម្រោង

| | |
|---|---|
| ៦. ប្រភេទគម្រោង ៖ | គម្រោងជំនួយបច្ចេកទេស |
| ៧. ប្រភពហិរញ្ញប្បទាន៖ | បញ្ចូលគ្នារវាងថវិការ និងឥណទានផ្សេងៗ |

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ

បញ្ចកោណទី២. ការធ្វើពិពិធកម្មសេដ្ឋកិច្ច និងការបង្កើនភាពប្រកួតប្រជែង

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

គម្រោងនេះ

នឹងចូលរួមចំណែកក្នុងការកសាងនិងអភិវឌ្ឍមូលដ្ឋានផលិតកម្មប្រកបដោយនិរន្តរភាពសម្រាប់ការកែច្នៃប្រកបដោយគុណភាព ការធ្វើពិពិធកម្មផលិតផលសក្តានុពល និងពិពិធកម្មទីផ្សារ ដើម្បីលើកកម្ពស់ភាពប្រកួតប្រជែងលើទីផ្សារតំបន់ និងសកល។

១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍ វិស័យឧស្សាហកម្មកម្ពុជា

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាដែរឬទេ ? គាំទ្រ

ការកែលម្អបរិស្ថាននិយ័តកម្ម (វិធានការសម្រួលពាណិជ្ជកម្ម និងជំរុញការនាំចេញ ការពង្រឹងបទដ្ឋានឧស្សាហកម្មនិងកម្មសិទ្ធិឧស្សាហកម្ម ការសម្រួលការបំពេញកាតព្វកិច្ចពន្ធនិងអាករ និងការរៀបចំទីផ្សារពលកម្មនិងទំនាក់ទំនងវិជ្ជាជីវៈ)

១១. វិស័យ (សូមប្រើវិស័យ អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ. )

| | |
|---|---|
| កម្មន្តសាល រ៉ែ និងពាណិជ្ជកម្ម | Industry and Support Services |
| | ការអភិវឌ្ឍន៍ទីផ្សារការងារ - Job development |

១២. ទីតាំងអនុវត្តគម្រោង (ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង)

គ្រប់ខេត្តក្រុង,

១៣. គោលបំណងរបស់គម្រោង (ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង)

- ធ្វើឱ្យប្រទេសកម្ពុជាក្លាយជាទីផលិត និងកែច្នៃ
- ជាអ្នកផ្គត់ផ្គង់មួយដែលអាចជឿទុកចិត្តបានសម្រាប់ទីផ្សារតំបន់ និងសកល
- ពិពិធកម្មផលិតផល និងទីផ្សារ ដើម្បីលើកកម្ពស់ការនាំចេញរបស់កម្ពុជា

១៤. ការពិពណ៌នាអំពីគម្រោង (ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង)

- ផ្តោតសំខាន់លើវិស័យអាទិភាពដែលរាជរដ្ឋាភិបាលកំពុងយកចិត្តទុកដាក់ ដោយពិចារណាលើផលិតផលសក្តានុពល ទីផ្សារគោលដៅ ដោយកំណត់បញ្ហាប្រឈមដែលវិស័យទាំងនេះកំពុងជួបប្រទះ ដើម្បីអាចដាក់ចេញនូវវិធានការសមស្របចាំបាច់
- ផ្លាស់ប្តូរពីផលិតកម្មបែបប្រពៃណី ឬគ្រួសារ ទៅជាផលិតកម្មបែបពាណិជ្ជកម្ម និងអនុវត្តតាមគោលការណ៍បច្ចេកទេស ដែលកសិករអាចទទួលបានប្រាក់ចំណូលក្នុងបរិបទដែលថ្លៃផលិតផលកសិកម្ម ឬកសិ-ឧស្សាហកម្មប្រែប្រួលការប្រើប្រាស់ដីប្រកបដោយនិរន្តរភាព និងកសិកម្មវៃឆ្លាតដែលធន់នឹងការប្រែប្រួលអាកាសធាតុ
- គាំទ្រដល់អ្នកកែច្នៃផលិតផលដែលមានសក្តានុពល និងទាក់ទាញវិនិយោគ ដើម្បីកែច្នៃផលិតផលដែលមានតម្លៃបន្ថែមសម្រាប់ផ្គត់ផ្គង់ទីផ្សារនានា
- ផ្សព្វផ្សាយអំពីទីផ្សារថ្មីៗ ដែលកម្ពុជាទើបទទួលបានពីការចរចាបង្កើតកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី បន្ថែមពីលើទីផ្សារប្រព័ន្ធអនុគ្រោះពន្ធដែលមានស្រាប់
- លើកកម្ពស់ភាពប្រកួតប្រជែងពាណិជ្ជកម្ម តាមរយៈការបញ្ច្រាបចូលនិងចាប់យកចំណែកទីផ្សារ កែលម្អកិច្ចសម្រួលពាណិជ្ជកម្ម កាត់បន្ថយចំណាយដែលមិនចាំបាច់ និងផ្សារភ្ជាប់នឹងអន្តរវិស័យដែលពាក់ព័ន្ធក្នុងការនាំចេញ។

១៥. យុត្តិកម្មលើគម្រោង (បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស)

ប្រសិនបើគោលនយោបាយជាតិបានតាក់តែង និងចងក្រងបានជោគជ័យ នោះវាបានបង្កើត ក៏ដូចជាផ្តល់ឱកាសការងារដល់ប្រជាពលរដ្ឋនៅជនបទដោយផ្ទាល់។ បន្ថែមពីលើនេះគោលនយោបាយទាំងនេះ នឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការទាញយកប្រយោជន៍ជាអតិបរមា និងការអភិវឌ្ឍន៍ជំណាំកសិ-ឧស្សាហកម្មទាំងនេះឱ្យក្លាយជាកម្លាំងចលករដ៏ខ្លាំងក្លា និងជំរុញសម្រេចគោលដៅក្នុងការប្រែក្លាយទៅជាប្រទេសនាំចេញផលិតផលកសិកម្មកែច្នៃ និងមានចំណូលមធ្យមកម្រិតខ្ពស់ឆ្នាំ ២០៣០។

១៦. ផលប្រយោជន៍របស់គម្រោង (រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង)

- ការជំរុញ និងអភិវឌ្ឍវិស័យនិងផលិតផលសក្តានុពលរបស់កម្ពុជា
- ការបង្កើនផលិតភាពនៃផលិតកម្ម និងសមត្ថភាពក្នុងការកែច្នៃក្នុងស្រុក តាមរយៈ ការកាត់បន្ថយថ្លៃដើមផលិតកម្ម និងការលើកទឹកចិត្តផ្សេងៗ
- លើកកម្ពស់ការចូលរួមចំណែករបស់វិស័យឯកជន និងភាគីពាក់ព័ន្ធ ដើម្បីស្វែងយល់ពីបញ្ហាប្រឈមរបស់ពួកគេ និងស្វែងរកដំណោះស្រាយសមស្រប ដើម្បីឱ្យពួកគេអាចមានលទ្ធភាពប្រកួតប្រជែង ជ្រៀតចូល និងក្តោបក្តាប់ចំណែកទីផ្សារក្នុងតំបន់ និងសកលបាន
- លើកកម្ពស់ការចូលរួមក្នុងខ្សែច្រវាក់តម្លៃតំបន់ និងសកល ស្របតាម ទីផ្សារ និងលក្ខខណ្ឌរបស់ទីផ្សារនាំចូល
- ជំរុញការធ្វើពិពិធកម្មផលិតផល និងទីផ្សារនាំចេញរបស់កម្ពុជា
- ជំរុញបង្កើនភាពប្រកួតប្រជែងនៃវិស័យកសិកម្ម និងកសិកម្មកែច្នៃ អនុវត្តក្នុងទម្រង់ភាពជាដៃគូរវាងរដ្ឋនិងឯកជន ដើម្បីលើកកម្ពស់វិស័យកសិកម្ម និងកសិកម្មកែច្នៃ ទៅជាឧស្សាហកម្មកែច្នៃផលិតផលសម្រេចមានតម្លៃបន្ថែមច្រើន។

១៧. ការសិក្សាសមិទ្ធិលទ្ធភាព

| | |
|---|---|
| តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ? | មាន |
| ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ? | មិនទាន់ចាប់ផ្តើម |

**១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម** (ពិពណ៌សង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញ ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?)

**គម្រោងនេះ នឹងមិនមានផលប៉ះពាល់ដល់បរិស្ថាន និងប្រជាជនទេ**
**ប៉ុន្តែនឹងចូលរួមអភិវឌ្ឍជំនាញនិងលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាជន ដែលនឹងចូលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ។**

**១៩. ការប្រែប្រួល អាកាសធាតុ**

ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? **គ្មាន**

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុ |
|---|---|---|

**២០. ការកាត់បន្ថយ ហានិភ័យ និង គ្រោះមហន្តរាយ**

តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយដែរឬទេ? **គ្មាន**

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្តេច? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

**លើកកម្ពស់សមភាពយេនឌ័រ ក្នុងវិស័យកសិកម្ម និងវិស័យកសិ-ពាណិជ្ជកម្ម**

**២២. សមត្ថភាពអនុវត្តគម្រោង** (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

**ក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោង ប៉ុន្តែក៏ត្រូវមានការជួយសហការចូលរួមពីអ្នកជំនាញជាតិ និងអន្តរជាតិ ដើម្បីធ្វើការបណ្តុះបណ្តាលបន្ថែមផងដែរ។**

**២៣. ស្ថានភាពនៃការអនុវត្តគម្រោង** (ពិពណ៌នាសង្ខេបអំពីវឌ្ឍនភាពរបស់គម្រោងនិងបង្ហាញអំពីភាពប្រឈមនានា ដែល បណ្តាលឲ្យមាន ការព្យាពេលក្នុងការអនុវត្តគម្រោង។)

**មិនទាន់មានការអនុវត្តបានពេញលេញនៅឡើយ ដោយសារបញ្ហាជម្ងឺកូវីដ១៩ និងមិនទាន់មានធនធានគ្រប់គ្រាន់ក្នុងការអនុវត្តគម្រោង និងទាមទារឱ្យមានការចូលរួមពីអ្នកពាក់ព័ន្ធទាំងអស់។**

**២៤. អាទិភាពរបស់គម្រោង** (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

5

**២៥. ការចូលរួមរបស់ដៃគូអភិវឌ្ឍ** (ផ្តល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្តានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

អង្គការ HEKs, CIRD, Grow Asia, HAVEST II បានចូលរួមជាជំនួយបច្ចេកទេសសម្រាប់គោលនយោបាយស្វាយចន្ទី
អង្គការ UNDP បានចូលរួមជាជំនួយបច្ចេកទេសសម្រាប់គោលនយោបាយជំឡូងមី។

## ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លារអាមេរិក)*

| ចំណាយវិនិយោគ | 2023 | | 2024 | 2025 | 2026 | 2027 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2025-2027 | ចរន្ត |
| **ចំណាយប្រតិបត្តិ** | 9.0 | 0.0 | 0.0 | 267.0 | 167.0 | 167.0 | 601.0 | 0.0 |
| | | | | | | | | |
| បៀវត្សរ៍ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សម្ភារៈនិងរដ្ឋបាល | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 9.0 | 0.0 | 0.0 | 267.0 | 167.0 | 167.0 | 601.0 | 0.0 |
| | | | | | | | | |
| **ចំណាយមូលធន** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សេវាទីប្រឹក្សា | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ទព្វសម្ភារៈ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ការបណ្តុះបណ្តាល | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយសរុប** | 9.0 | 0.0 | 0.0 | 267.0 | 167.0 | 167.0 | 601.0 | 0.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2023 | | 2024 | 2025 | 2026 | 2027 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2025-2027 | |
| | | | | | | | | |
| ចំណូលពីគម្រោង | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ថវិកាជាតិ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| ធនធានផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម | 9.0 | 0.0 | 0.0 | 267.0 | 167.0 | 167.0 | 601.0 | |

**បានឃើញ និង ឯកភាព**

**រដ្ឋមន្ត្រី**

កាលបរិច្ឆេទ: